# មេរៀនទី ១៤៦៖ យ៉ូណាសរៀនបទពិសោធន៍មកពីព្រះ

## យ៉ូណាស ១-៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ToPxsKhAC8o

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/tnPeNozuA-c

**គោលបំណង៖ ផ្លូវរបស់ព្រះគឺល្អបំផុត។**

**ខគម្ពីរចងចាំ៖ មីកា ៦៖៨** *"ឱមនុស្សអើយ ព្រះបានបង្ហាញឲ្យឯងស្គាល់សេចក្ដីដែលល្អ តើព្រះយេហូវ៉ាសព្វព្រះហឫទ័យឲ្យឯងប្រព្រឹត្តដូចម្តេច បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត ឲ្យស្រឡាញ់សេចក្តីសប្បុរស ហើយឲ្យដើរជាមួយនឹងព្រះនៃខ្លួន ដោយសុភាពរាបទាបប៉ុណ្ណោះ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់https://youtu.be/I-PzUIJ0MVo

២.ខ្ញុំរត់ពីព្រះជាម្ចាស់មិនបាន https://youtu.be/e3O9GqwVGCk

៣.មួយ ពីរ ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/32BRXvDba4w

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ឆ្វេងនិងស្តាំ»



១. ឲ្យកុមារឈរជារង្វង់ ដោយកាន់ដៃគ្នា គ្រូជាអ្នកស្រែកបញ្ជា ហើយកុមារ លោតតាមការស្រែករបស់គ្រូ

២. គ្រូត្រូវស្រែកប្រាប់កុមារឲ្យធ្វើតាមពាក្យរបស់គាត់បើ គ្រូស្រែកថាស្តាំ កុមារត្រូវលោតទៅស្តាំ បើគ្រូស្រែកថា ឆ្វេង កុមារត្រូវលោតទៅឆ្វេង បើគ្រូស្រែកថាទៅក្រោយ កុមារត្រូវលោតទៅក្រោយ ហើយបើគ្រូស្រែកថាទៅ មុខ កុមារត្រូវលោតទៅមុខ។




៣. សូមលេងម្តងទៀត មុនពេលចាប់ផ្តើមលេង ម្តងនេះកុមារត្រូវស្តាប់ឲ្យជាក់ ព្រោះកុមារត្រូវលោតផ្ទុយ និងពាក្យ ដែលគ្រូស្រែក ប្រសិនបើគ្រូស្រែកថាលោតទៅមុខ កុមារត្រូវលោតទៅក្រោយ គ្រូស្រែកលោតទៅឆ្វេង កុមារត្រូវលោតទៅស្តាំ គ្រូស្រែកឲ្យកាន់តែលឿន បើកុមារលោតខុសគាត់មិនអាចបន្តលេងល្បែងនេះបានទេ។

៤. បន្ទាប់ពីលេងល្បែងចប់សូមពន្យល់កុមារថា ពេលខ្លះយើងច្រលំពីអ្វីដែលយើងត្រូវធ្វើ តែព្រះដឹងគ្រប់យ៉ាងពីយើង ហើយព្រះអង្គតែងតែជួយដល់យើង។

### ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់វង្វេងផ្លូវទេ? តើអ្នកនឹងសួរអ្នកណាដើម្បីបង្ហាញផ្លូវដល់អ្នក? តើអ្នកនឹងសួរកូនង៉ែតឬ? តើអ្នកនឹងសួរកូនក្មេងឬ? តើអ្នកនឹងមិនសួរចាស់ទុំដែលស្គាល់ទិសដៅឬទេ? តើអ្នកណាដែលអ្នកគិតថាស្គាល់ផ្លូវល្អបំផុតសំរាប់យើង? ព្រះដឹងថាអ្វីដែលល្អបំផុតសំរាប់យើង ហើយព្រះអង្គតែងតែចង់ដឹកនាំបង្ហាញផ្លូវដល់យើង! ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលមិនស្តាប់តាមការដឹកនាំរបស់ព្រះ ហើយបុរសម្នាក់នោះត្រូវបានត្រីដ៏ធំមួយលេបចូលទៅក្នុងពោះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ គឺនិយាយពីបុរសម្នាក់ឈ្មោះថា យ៉ូណាស។ គាត់គឺជាហោរាម្នាក់ដែលជាអ្នកប្រាប់មនុស្សពីអ្វីដែលព្រះមានបន្ទូល។ ថ្ងៃមួយ ព្រះបានប្រាប់ឲ្យគាត់ធ្វើដំណើរទៅទីក្រុង នីនីវេ ដើម្បីប្រាប់ពួកគេពីអ្វីដែលព្រះមានបន្ទូលទៅកាន់ពួកគេ។ ព្រះចង់ឲ្យយ៉ូណាសប្រាប់ពួកគេថា ប្រសិនបើពួកគេមិនបញ្ឈប់ផ្លូវបាបរបស់ពួគគេទេ ដូច្នេះព្រះនឹងដាក់ទោសពួកគេ។

ប៉ុន្តែយ៉ូណាស មិនចង់ធ្វើដំណើរទៅទីក្រុង នីនីវេ និងប្រាប់ពួកគេអំពីព្រះនោះទេ។ នេះក៏ព្រោះតែក្រុងនីនីវេគឺជាសត្រូវរបស់ជនជាតិអ៊ីស្រាអែល។ ប្រជាជននៃក្រុងនីនីវេមិនមែនជាជនជាតិយូដាទេ ហើយពួកគេបានធ្វើបាបជនជាតិអ៊ីស្រាអែល។ យ៉ូណាសមិនចង់សង្គ្រោះសត្រូវរបស់អ៊ីស្រាអែលទេ។

ដូច្នេះគាត់បានសំរេចចិត្តរត់ចេញឆ្ងាយពីព្រះ។ គាត់បានឡើងជិះលើនាវាមួយធ្វើដំណើរបញ្ច្រាស់ទិសគ្នាជាមួយនឹងផ្លូវទៅទីក្រុងនីនីវេ ហើយគាត់បានព្យាយាមទៅឲ្យឆ្ងាយពីទីក្រុងនីនីវេ។ ប៉ុន្តែមានព្យុះមួយយ៉ាងធំបានបក់មកកាន់នាវាដែលគាត់ជិះ ហើយនាយនាវាមិនដឹងថាត្រូវធ្វើយ៉ាងមិច។ គ្រប់គ្នានៅលើនាវាកំពុងតែជិតស្លាប់។ បន្ទាប់មកយ៉ូណាសបានប្រាប់នាយនាវាថាគាត់មិនស្តាប់បង្គាប់ព្រះ នេះជាហេតុដែលធ្វើឲ្យមានខ្យល់ព្យុះនេះកើតឡើង។ យ៉ូណាសបានប្រាប់ពួកគេឲ្យបោះគាត់ចូលទៅក្នុងសមុទ្រចុះ ដូច្នេះព្យុះនឹងស្ងប់។ នៅពេលដែលនាយនាវាបានបោះគាត់ចូលទៅក្នុងទឹក ព្យុះក៏បានស្ងប់ទៅវិញ។

ព្រះមិនបានមានន័យឲ្យយ៉ូណាសស្លាប់នៅក្នុងសមុទ្រទេ ដូច្នេះព្រះអង្គបានរៀបចំត្រីដ៏ធំមួយដើម្បីលេបយ៉ូណាសចូលទៅក្នុងពោះ ហើយរក្សាគាត់ឲ្យមានសុវត្ថិភាព រហូតដល់គាត់ត្រៀមខ្លួនរួចជាស្រេចក្នុងការស្តាប់បង្គាប់ព្រះ ពីព្រោះផ្លូវរបស់ព្រះគឺល្អបំផុត។ បន្ទាប់ពីបាន៣ថ្ងៃ យ៉ូណាបានអធិស្ឋាន ហើយទូលទៅព្រះ ថាគាត់នឹងធ្វើដំណើរទៅទីក្រុងនីនីវេ និងប្រាប់ប្រជាជននៅនីនីវេអំពីព្រះ។

ព្រះបានឲ្យត្រីនាំយ៉ូណាសធ្វើដំណើរទៅនីនីវេ ហើយត្រីបានក្អែរគាត់ចេញនៅទីនោះ ហើយយ៉ូណាសបានប្រាប់ប្រជាជននៅនីនីវេឲ្យឈប់ធ្វើបាបទៀត ពួកគេជឿលើព្រះ ហើយបានរើសធ្វើការល្អ! ព្រះបានសង្គ្រោះទីក្រុងនីនីវេតាមរយៈយ៉ូណាស ទោះបីជាពួកគេជាសត្រូវជាមួយអ៊ីស្រាអែលក៏ដោយ!

ព្រះស្រឡាញ់មនុស្សគ្រប់គ្នាទាំងអស់! ព្រះចង់ឲ្យយើងស្រឡាញ់មនុស្សគ្រប់គ្នាដូចព្រះអញ្ចឹងដែរ! ព្រះចង់ឲ្យយើងប្រព្រឹត្តដោយយុត្តិធម៌គឺមានន័យថាត្រឹមត្រូវ និងយុត្តិធម៌នៅក្នុងការប្រព្រឹត្តរបស់យើង។ ព្រះចង់ឲ្យយើងស្រឡាញ់ក្តីមេត្តាករុណា ដែលមានន័យថាព្រះអង្គចង់ឲ្យយើងយកចិត្តទុកដាក់ចំពោះអ្នកដទៃមានក្តីមេត្តាចំពោះគ្នា និងអត់ទោសឱ្យគ្នាទោះបីជាពួកគេមិនសមនឹងទទួលវាក៏ដោយ។ ហើយព្រះចង់ឲ្យយើងដើរដោយបន្ទាបខ្លួនជាមួយនឹងព្រះអង្គ។ ដែលមានន័យថាព្រះអង្គចង់ឲ្យយើងទុកចិត្តទ្រង់ ហើយចងចាំថាផ្លូវរបស់ព្រះអង្គគឺល្អបំផុត។ ព្រះស័ក្តិសមនឹងទទួលបាននូវការប្រព្រឹត្តរបស់យើង ពីព្រោះផ្លូវរបស់ព្រះគឺល្អបំផុត។

## ៦. សំនួរពិភាក្សា

១. តើហោរ៉ានៅក្នុងសាច់រឿងព្រះគម្ពីរថ្ងៃនេះមានឈ្មោះអ្វី? *(យ៉ូណាស)*

២. តើព្រះបានឲ្យគាត់ធ្វើអ្វីខ្លះ? *(ព្រះឲ្យគាត់ធ្វើដំណើរទៅនីនីវេ និងសង្គ្រោះពួកគេចេញពីអំពើបាប)*

៣. ហេតុអ្វីបានជាយ៉ូណាសមិនចង់ធ្វើដំណើរទៅទីក្រុងនីនីវេ?
*(ពីព្រោះប្រជាជននៅនីនីវេធ្វើបាបជនជាតិអ៊ី ស្រាអែល ពួកគេគឺជាសត្រូវរបស់អ៊ីស្រាអែល)*

៤. ហេតុអ្វីបាជាព្រះចង់សង្គ្រោះនីនីវេ ដែលជាសត្រូវរបស់អ៊ីស្រាអែល?
*(ពីព្រោះព្រះអង្គស្រឡាញ់មនុស្សគ្រប់គ្នា)*

៥. តើអ្នកនឹងធ្វើអ្វីខ្លះពេលដែលព្រះឲ្យអ្នកធ្វើអ្វីមួយដែលអ្នកមិនចូលចិត្ត? *(ឲ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ស្តាប់តាមអ្នកនៅក្រោយ»

សម្ភារៈដែលត្រូវការ៖ ក្រមា កន្រ្តក ឬចានដែក គ្រាប់ប៉េងប៉ុង

១. ចែកកុមារជា ២ ឬ ៣ ក្រុម ឲ្យពួកគេឈរជាជួរ



២. ប្រើក្រមារុំភ្នែកកុមារទាំងអស់ លើកលែងតែកុមារចុងក្រោយម្នាក់ប៉ុណ្ណោះ
៣.គ្រូនឹងដាក់គ្រាប់ប៉េងប៉ុងនៅគ្រប់កន្លែងទាំងអស់នៅក្នុងថ្នាក់រៀន។
៤. ឲ្យកុមារដាក់ដៃនៅលើស្មាបន្តបន្ទាប់គ្នារហូតដល់កុមារនៅខាងមុខ។ ពួកគេត្រូវតោងគ្នាឲ្យជាប់នៅពេលលេងល្បែងនេះ។ កុមារដែលនៅក្រោយគេត្រូវទះស្មារបស់កុមារខាងមុខ ដើម្បីប្រាប់កុមារនៅខាងមុខឲ្យដើរទៅខាងឆ្វេង ឬទៅខាងស្តាំ។ ពួកគេត្រូវដើរទៅស្តាំ ទៅឆ្វេងតាមតម្រុយដែលកុមារនៅ ខាង ក្រោយគេផ្តល់ឲ្យ ហើយពួកគេត្រូវផ្លាស់ទីជាក្រុម ហើយបើទះស្មាទាំងពីរ ពួកគេត្រូវឈប់ហើយរើសប៉េងប៉ុង ។ ក្រុមណាដែលអាចស្វែងរកគ្រាប់ប៉េងប៉ុងបានច្រើនជាង គេក្រុមនោះ ជាអ្នកឈ្នះ។
៥ .បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ក៏ដូចជាការដែលយើងស្តាំតាមការណែនាំ របស់កុមារដែលនៅខាងក្រោយអីចឹង ពួកយើងគឺត្រូវតែស្តាំតាមព្រះជានិច្ចពីព្រោះព្រះគឺជ្រាបដឹងគ្រប់យ៉ាងទាំងអស់។

## ៨. ខគម្ពីរចងចាំ

**មីកា ៦៖៨** *"ឱមនុស្សអើយ ព្រះបានបង្ហាញឲ្យឯងស្គាល់សេចក្តីដែលល្អ តើព្រះយេហូវ៉ាសព្វ ព្រះហឫទ័យ ឲ្យឯងប្រព្រឹត្តដូចម្តេច បើមិនមែនឲ្យប្រព្រឹត្តដោយសុចរិត ឲ្យស្រឡាញ់សេចក្តី សប្បុរស ហើយឲ្យដើរជាមួយនឹងព្រះនៃខ្លួន ដោយសុភាពរាបទាបប៉ុណ្ណោះ។"*

## ៩. ហាត្ថកម្ម "យ៉ូណាសរៀនបទពិសោធន៍ពីព្រះ"



សម្ភារៈដែលត្រូវការ៖ កូល័រ កន្ត្រៃ ការបិត
១. ផាត់ព៌ណត្រីបាឡែន និងកាត់វាចេញមក។
២. កាត់គំនូសដាច់ៗដែលនៅលើត្រីបាឡែន (កុំកាត់ផ្នែកខាងលើ)។
៣. កាត់រូបយ៉ូណាសចេញជារូបចតុកោណកែង។
៤.
បិតរូបយ៉ូណាសនៅខាងក្រោយកន្លែងបើកសន្ទះលើរូបត្រីបាឡែនដូច្នេះពេលដែលអ្នកបើកសន្ទះនោះ អ្នកអាចឃើញរូបយ៉ូណាសនៅពីខាងក្រោយ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
តើអ្នកនឹងបែរទៅរកអ្នកណាពេលដែលអ្នកត្រូវការដឹកនាំផ្លូវ? ក្នុងចំណោមអ្វីៗជាច្រើនដែលខុសគ្នាជាមួយនឹងការសម្លឹងមើលរបស់មនុស្ស មានតែព្រះទេដែលដឹកនាំផ្លូវដ៏ល្អបំផុតសំរាប់ជីវិតយើង។ បើយើងមានការសង្ស័យអំពីអ្វីជាទិសដៅដែលនាំមកក្នុងជីវិតយើង យើងតែងតែអាចស្វែងរកជំនួយមកពីព្រះ។ អរគុណព្រះសំរាប់ទិសដៅដ៏ស្មោះត្រង់របស់ព្រះនៅក្នុងជីវិតរបស់យើង។ ទូលសុំព្រះឲ្យជួយអ្នកស្តាប់បង្គាប់ និងត្រៀមខ្លួនធ្វើសកម្មភាពនៅពេលដែលព្រះមានបន្ទូល។ ការដ៏អស្ចារ្យជាច្រើននឹងអាចកើតឡើងនៅពេលដែលយើងបើកចិត្តទទួលយកការដឹកនាំផ្លូវរបស់ព្រះ។

យ៉ូណាសរៀនបទពិសោធន៍ពីអ្វីដែលបានកើតឡើង







ការណែនាំ៖

១. ផាត់ពណ៌ត្រីបាឡែន ហើយវាចេញមក។

២. កាត់គំនូសដាច់ៗដែលនៅលើត្រីបាឡែន (កុំកាត់ផ្នែកខាងលើគេ)

៣. កាត់រូបយ៉ូណាសចេញជារាងចតុកោណកែង។

៤. បិតរូបយ៉ូណាសនៅខាងក្រោយកន្លែងបើកសន្ទះលើរូបត្រីបាឡែន ដូច្នេះពេលដែលបើកសន្ទះនឹងឡើង អ្នកអាចឃើញរូបយ៉ូណាស់នៅខាងក្រោយសន្ទះនោះ